# ព្រះគម្ពីរសម្រាប់កុមារ
## សូមបង្ហាញជូន

# ព្រះរាជកំណើតនៃព្រះយេស៊ូវ




និពន្ធដោយ: Edward Hughes
បកប្រែដោយ: Christian Lingua
ធ្វើការពន្យល់ដោយ: M. Maillot
កែសម្រួលដោយ: E. Frischbutter; Sarah S.



រឿងទី ៣៦ ក្នុងចំណោម ៦០

**www.M1914.org**

***Bible for Children,*** *PO Box 3, Winnipeg, MB R3C 2G1 Canada*


អាជ្ញាប័ណ្ណ៖ អ្នកមានសិទ្ធិក្នុងការចម្លង ឬបោះពុម្ពរឿងនេះបាន ដរាបណាអ្នកមិនយកទៅលក់។

ភាសាខ្មែរ Khmer







នាងក៏បានសួរទាំងក្ដីអស្ចារ្យក្នុងចិត្តថា
តើការនេះនឹងកើតដូចម្ដេចបាន
បើខ្ញុំមិនដែលស្គាល់ប្រុសណាផង
ទេវតាក៏បានប្រាប់នាងម៉ារាថា
បុត្រានោះនឹងត្រូវយាងមកពីព្រះ។
ទ្រង់មិនចាំបាច់ត្រូវការ
ឪពុកជាមនុស្សឡើយ។
3


ទេវតាបានប្រាប់នាងម៉ារាថា បងស្រីជីដូនមួយ
របស់នាងគឺអេលីសាបែតក៏កំពុងតែមានគភ៌
ក្នុងកាលដែលមានអាយុចាស់ហើយនោះផង។
4


នេះក៏ជាការអស្ចារ្យមួយដែរ។
ក្រោយមកមិនយូរប៉ុន្មាន
នាងម៉ារាក៏បានមកលេង
នឹងអេលីសាបែត។
ពួកគាត់បានសរសើរ
តម្កើងដល់ព្រះទាំង
អស់គ្នា។
5


នាងម៉ារាបានភ្ជាប់ពាក្យជាគូ
ដណ្ដឹងជាមួយនឹងបុរសម្នាក់
ឈ្មោះយ៉ូសែប។ លោកយ៉ូសែប
មានចិត្តព្រួយ ដោយគាត់
បានដឹងថា
ម៉ារាមានគភ៌។
គាត់បានគិតថា
ប្រហែលជាឪពុក
របស់កូននោះគឺ
ជាបុរសណាម្នាក់
ផ្សេងហើយ។
6


នៅក្នុងការយល់សប្ដ
ទេវតារបស់ព្រះបានប្រាប់លោកយ៉ូសែប
ថា បុត្រនោះគឺជាព្រះរាជបុត្រារបស់ព្រះ។
លោកយ៉ូសែបត្រូវធ្វើជាជំនួយដល់
នាងម៉ារាដើម្បីមើលថែព្រះយេស៊ូវ។
7


លោកយ៉ូសែបបានទុកចិត្ត
ហើយស្ដាប់បង្គាប់ព្រះ។
គាត់ក៏ជាដែលស្ដាប់បង្គាប់
ច្បាប់នៅក្នុងប្រទេសរបស់
គាត់ផងដែរ។
8


ពីព្រោះតែច្បាប់ថ្មី ទើបគាត់ និងនាងម៉ារាត្រូវចេញដំណើរ
ទៅឯស្រុកកំណើតរបស់ពួក
គាត់ គឺភូមិបេថ្លេហិម
ដើម្បីនឹងចុះបញ្ជីបង់ពន្ធ។
9


នាងម៉ារាដល់ពេលដែល
ត្រូវសម្រាលបុត្រហើយ។
ប៉ុន្តែ លោកយ៉ូសែបមិន
អាចរកបន្ទប់ស្នាក់នៅ
មួយសោះ។ គ្រប់ទាំង
អស់សំណាក់សុទ្ធតែ
ពេញអស់ហើយ។
10


ចុងក្រោយ លោកយ៉ូសែបរកបានក្រោលសត្វមួយ។ នៅទី
នោះហើយដែលព្រះឱរសយេស៊ូវបានប្រសូតមក។ មាតាទ្រង់
បានដាក់ទ្រង់នៅក្នុងស្នូកសត្វ
ដែលជាធម្មតាគឺជា
កន្លែងសម្រាប់
ដាក់ចំណី
សត្វ។
11


នៅមិនឆ្ងាយពីទីនោះដែរ មានពួកអ្នកគង្វាលដែល
ចាំយាមរក្សាហ្វូងចៀមរបស់ពួកគេ។
12


នោះទេវតានៃព្រះបានលេចមកហើយប្រាប់ដល់ពួកអ្នក
គង្វាលអំពីដំណឹងល្អដ៏អស្ចារ្យមួយ។
13


“នៅថ្ងៃនេះ មានព្រះសង្គ្រោះ១អង្គបានប្រសូតដល់អ្នករាល់គ្នា
នៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទជាព្រះ
អម្ចាស់។
14


អ្នករាល់គ្នានឹងឃើញព្រះឱរសដែលកំពុងផ្ដេកនៅក្នុង
ស្នូកសត្វមួយ។”
15


រំពេចនោះ ស្រាប់តែមានពួកទេវតាដ៏ភ្លឺ
ចែងចាំងយ៉ាងច្រើនកុះករលេចមក
ក៏ពោលសរសើរតម្កើងព្រះ ដោយពា
ក្យថា ...
16


... “សូមថ្វាយសិរីល្អដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត
ហើយសូមឲ្យសេចក្ដីសុខសាន្តមាននៅ
ផែនដី ...
17


... នៅកណ្ដាលមនុស្ស ដែលជាទីគាប់ព្រះ
ហឫទ័យដល់ទ្រង់។”
18


ពួកអ្នកគង្វាលក៏ប្រញាប់ទៅឯក្រោយសត្វ។
ក្រោយដែលបានឃើញព្រះឱរសហើយ ...
19


... នោះពួកគេក៏បានដំណាលប្រាប់ដល់
មនុស្សគ្រប់គ្នាទាំងឡាយណាដែលពួកគេ
បានជួប អំពីការដែលពួកទេវតាបានថ្លែង
ប្រាប់រឿងព្រះយេស៊ូវនោះ។
20


សែសិបថ្ងៃក្រោយមក យ៉ូសែប និង
នាងម៉ារាបាននាំព្រះយេស៊ូវទៅឯព្រះ
វិហារនៅក្រុងយេស៊ូវសាឡិម។
មានបុរសម្នាក់ឈ្មោះ
ស៊ីម្មានបានសរសើរដល់
ព្រះដោយព្រះបានឃើញ
ព្រះឱរស រីឯនាងអាណ
ដែលជាស្ត្រីវ័យចំ
ណាស់ម្នាក់
និងជាអ្នក
បម្រើដល់ព្រះផង
នាងក៏ថ្លែងអរព្រះ
គុណដល់ព្រះដែរ។
21


អ្នកទាំងពីរសុទ្ធតែដឹងថា ព្រះយេស៊ូវ
គឺជាព្រះរាជបុត្រានៃព្រះ គឺជាព្រះអង្គ
សង្គ្រោះដែលបានសន្យាថា
នឹងត្រូវយាងមក។
លោកយ៉ូសែបបានថ្វាយ
សត្វស្លាបពីរចំពោះព្រះ។
22


នេះគឺជាគឺជាដង្វាយ
ដែលក្នុងក្រឹត្យវិន័យ
របស់ព្រះបានតម្រូវស
ម្រាប់អ្នកក្រីក្រ
ដែលត្រូវថ្វាយចំពោះព្រះ
នៅពេលពួកគេយក
កូនប្រុសជាចម្បងមក
ថ្វាយដល់ព្រះអម្ចាស់។
23


វេលាក្រោយមកទៀត
មានផ្កាយដ៏ពិសេស
មួយបាននាំផ្លូវពួក
អ្នកប្រាជ្ញមកពី
ទិសខាងកើត
ឲ្យធ្វើដំណើរមកដល់ទីក្រុងយេរូសាឡិម។
ពួកលោកបានសួរថា □តើបុត្រា
ដែលត្រូវប្រសូតមកធ្វើជាស្តេចនៃ
សាសន៍យូដានៅឯណា□ពួកយើងខ្ញុំ
ចង់ក្រាបថ្វាយបង្គំទ្រង់។□
24


ស្តេចហេរ៉ូឌបានឮអំពីពួក
អ្នកប្រាជ្ញនោះ។ ដោយមាន
ព្រះទ័យតក់ស្លុតផង ទ្រង់ក៏
បានសុំឲ្យពួកអ្នកប្រាជ្ញទាំង
នោះប្រាប់ដល់ទ្រង់វិញផង
នៅពេលដែលពួកលោករក
ឃើញព្រះយេស៊ូវ។ ទ្រង់មាន
បន្ទូលថា “យើងចង់ថ្វាយ
បង្គំទ្រង់ដែរ។” ប៉ុន្តែ ទ្រង់
កុហកទេ។ គឺស្តេចហេរ៉ូឌចង់
ធ្វើគុតព្រះយេស៊ូវ
ទៅវិញទេ។
25


ផ្កាយនោះបាននាំពួកអ្នកប្រាជ្ញាទៅដល់
ចំផ្ទះមួយដែលនាងម៉ារា និងយ៉ូសែប
កំពុងរស់នៅជាមួយនឹងព្រះកុមារ
យេស៊ូវ។ ពួកលោកក៏លុតជង្គង់ចុះ
ហើយថ្វាយបង្គំ ព្រមទាំងបាន
ថ្វាយព្រះយេស៊ូវនូវដង្វាយជាមាស់
និងកំញានដ៏
ច្រើនទៀតផង។
26













ព្រះរាជកំណើតនៃព្រះយេស៊ូវ

រឿងមួយដែលបានមកពីព្រះបន្ទូលរបស់ព្រះ
គឺជាព្រះគម្ពីរ

អាចរកឃើញនៅក្នុង

ម៉ាថាយ ១-២; លូកា ១-២

□ការបើកសំដែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញ។□
ទំនុកដំកើង ១១៩□១៣០

ព្រះអង្គជ្រាបថាយើងបានប្រព្រឹត្តអំពើអាក្រក់
ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។
ទោសនៃអំពើបាបគឺជាសេចក្តីស្លាប់។

ព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់
ដល់ម្លេះបានជាទ្រង់បានចាត់ព្រះយេស៊ូវជាព្រះរាជបុត្រាតែ១របស់ព្រះអង្គ
ឲ្យមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។
ព្រះយេស៊ូវបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រឡប់ទៅស្ថានសួគ៌!
ឥឡូវនេះ ព្រះអង្គអាចអភ័យទោសអស់ទាំងអំពើបាបរបស់យើងបាន។

ប្រសិនបើអ្នកចង់បែរចេញពីអំពើបាបរបស់អ្នក
នោះអ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖
ព្រះអង្គអើយ ខ្ញុំជឿហើយថា ព្រះយេស៊ូវបានសុគតជំនួសខ្ញុំ
ហើយទ្រង់ក៏មានព្រះរស់ឡើងវិញហើយរហូតដល់ឥឡូវនេះមែន។
សូមទ្រង់យាងចូលមកក្នុងជីវិតរបស់ខ្ញុំ
ហើយអភ័យទោសអំពើបាបទាំងប៉ុន្មានរបស់ខ្ញុំ
ដើម្បីឲ្យខ្ញុំអាចរស់នៅក្នុងជីវិតថ្មីនាពេលឥឡូវនេះ
ហើយបន្ទាប់មកនឹងបានទៅនៅជាមួយទ្រង់ជារៀងរហូត។
សូមជួយខ្ញុំឲ្យបានរស់នៅសម្រាប់ទ្រង់ក្នុងនាមជាមួយរបស់ទ្រង់។
អាម៉ែន។ យ៉ូហាន ៣:១៦

សូមអានព្រះគម្ពីរ ហើយអធិស្ឋានទូលទៅកាន់ព្រះជារៀងរាល់ថ្ងៃ!